# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០១ . សប្រក

## សេចក្ដីប្រកាស

## ស្ដីអំពីការតែងតាំងក្រសួងបរិស្ថាន

## ជាស្ថាប័នបណ្ដោះអាសន្ន ទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាត

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៥ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ស្ដីពីការប្រកាសឱ្យប្រើច្បាប់ស្ដីពីការអនុម័តយល់ព្រមលើអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្ដីពីការប្រែប្រួលអាកាសធាតុ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ-បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងលិខិតូបករណ៍ចូលរួមជាសមាជិកពេញសិទ្ធិនៃពិធីសារក្យូតូ ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០២ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

# សំរេច

## ប្រការ ១

តែងតាំងក្រសួងបរិស្ថាន ជា ស្ថាប័នបណ្ដោះអាសន្ន ទទួលបន្ទុកយន្ដការអភិវឌ្ឍន៍ស្អាត ដោយអនុលោមតាមពិធីសារក្យូតូ ព្រមទាំងបែបបទ និងនីតិវិធីនានា ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងម៉ារ៉ាកិច (The Marrakech Accords) ។

## ប្រការ ២

ក្រសួងបរិស្ថាន ក្នុងនាមជា ស្ថាប័នបណ្ដោះអាសន្នទទួលបន្ទុកយន្ដការអភិវឌ្ឍន៍ស្អាត មានសិទ្ធិអំណាចតំរូវឱ្យម្ចាស់គំរោងយន្ដការអភិវឌ្ឍន៍ស្អាត បណ្ដាស្ថាប័ន ឬអ្នកពាក់ព័ន្ធនឹងគំរោងយន្ដការអភិវឌ្ឍន៍ស្អាតនានា ផ្ដល់ជូននូវពត៌មានចាំបាច់ ដែលទាក់ទងនឹងគំរោងយន្ដការអភិវឌ្ឍន៍ស្អាត ដែលខ្លួនស្នើឡើង ។

## ប្រការ ៣

ក្រសួងបរិស្ថាន ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយបណ្ដាក្រសួង និងស្ថាប័នពាក់ព័ន្ធនានា មានតួនាទី និងភារកិច្ចដូចតទៅ :

ក. រៀបចំលក្ខណៈវិនិច្ឆ័យសមស្រប សំរាប់ប្រើប្រាស់ក្នុងការវាយតំលៃលើគំរោងយន្ដការអភិវឌ្ឍន៍ស្អាត ដើម្បីធានាថា បណ្ដាគំរោងទាំងនោះគាំទ្រដល់គោលដៅអភិវឌ្ឍន៍ដោយចីរភាពនៅកម្ពុជា ។ នៅក្នុងការរៀបចំលក្ខណៈវិនិច្ឆ័យទាំងនេះ ក្រសួងបរិស្ថានត្រូវគោរពតាមច្បាប់ បទប្បញ្ញត្តិ គោលនយោបាយ ផែនការ កាតព្វកិច្ច សេចក្ដីថ្លែងការណ៍ និងប្រកាសនានាដែលមានជាធរមាន ។

ខ. វាយតំលៃលើគំរោងយន្ដការអភិវឌ្ឍន៍ស្អាតដែលស្នើឡើង ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ ដែលបានរៀបចំតាមចំនុច " ក " ខាងលើ

គ. ក្នុងករណីចាំបាច់ វាយតំលៃលើគំរោងយន្ដការអភិវឌ្ឍន៍ស្អាតដែលស្នើឡើង ដោយអនុលោមតាមបែបបទ និងនីតិវិធីនានា ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងម៉ារ៉ាកិច ឬនៅក្នុងសេចក្ដីសំរេចនានានៃកិច្ចប្រជុំប្រចាំឆ្នាំ របស់បណ្ដាភាគីជាសមាជិកនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្ដីពីការប្រែប្រួលអាកាសធាតុ ឬពិធីសារក្យូតូ ។

## ប្រការ ៤

ក្រសួងបរិស្ថាន ត្រូវចេញលិខិតអនុម័តជាលាយលក្ខណ៍អក្សរ ដើម្បីបញ្ជាក់ថា ក្នុងនាមជាប្រទេសទទួលអនុវត្តគំរោង ការចូលរួមរបស់កម្ពុជាក្នុងសកម្មភាពគំរោងយន្ដការអភិវឌ្ឍន៍ស្អាត ត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត ហើយថា តាមរយៈដំណើរការវាយតំលៃ ដូចមានចែងក្នុងប្រការ ៣ ចំណុច ខ ខាងលើ គំរោងដែលស្នើឡើងនឹងជួយឱ្យសំរេចនូវការអភិវឌ្ឍដោយចីរភាព នៅកម្ពុជា ។

**ប្រការ ៥**

ក្រសួងបរិស្ថានត្រូវទទួលបន្ទុកក្នុងការរៀបចំស្ថាប័នអចិន្ត្រៃយ៍ទទួលបន្ទុកកិច្ចការយន្តការអភិវឌ្ឍន៍ស្អាត ដោយសហការជាមួយបណ្តាក្រសួង និងស្ថាប័នរដ្ឋាភិបាល ក៏ដូចជាភាគីពាក់ព័ន្ធដទៃទៀត ។

**ប្រការ ៦**

ក្នុងករណីចាំបាច់ ក្រសួងបរិស្ថានត្រូវទទួលបន្ទុកអនុវត្តភារកិច្ចផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ស្ថាប័នបណ្តោះអាសន្នទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាត ជនបង្គោលនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ និងពិធីសារក្យូតូ ។

**ប្រការ ៧**

ក្រសួងបរិស្ថានត្រូវបំពេញមុខនាទីជាការិយាល័យទំនាក់ទំនង និងជាជនបង្គោល សំរាប់កិច្ចការទំនាក់ទំនងជាតិ និងអន្តរជាតិ ដែលពាក់ព័ន្ធនឹងយន្តការអភិវឌ្ឍន៍ស្អាត ហើយត្រូវជំរុញនិងសំរបសំរួលការវិនិយោគ ឬគំរោងយន្តការអភិវឌ្ឍន៍ស្អាត ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ។

**ប្រការ ៨**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៨
- ឯកសារ-កាលប្បវត្តិ